**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពត**

សំណុំរឿងរដ្ឋប្បវេណីលេខ២៧២
ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១
**សាលក្រមលេខ: ០៩ "ក"**
ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២

# សាលក្រម
# តាងនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងខេត្តកំពត

-បានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅសាលសវនាការ។

-កាលបរិច្ឆេទបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១ វេលារសៀល។

-កាលបរិច្ឆេទប្រកាសសាលក្រមនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០២២ វេលាព្រឹក។

## ចៅក្រមជំនុំជម្រះ

ឯកឧត្តម [redacted] ជាប្រធានសាលាដំបូងខេត្តកំពត

## ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ជាក្រឡាបញ្ជី នៃសាលាដំបូងខេត្តកំពត

**ដើមចោទ៖** ឈ្មោះ [redacted]គីមឡុង ភេទស្រី អាយុ៤៨ឆ្នាំ ជនជាតិខ្មែរ សញ្ញាតិខ្មែរ មុខរបរគ្រូបង្រៀន អាសយដ្ឋានបច្ចុប្បន្ននៅ[redacted]។

**ចុងចម្លើយ៖** ឈ្មោះ [redacted]ដារ៉ែន ភេទស្រី អាយុ៣៨ឆ្នាំ ជនជាតិខ្មែរ មុខរបរលក់ដូរ និងឈ្មោះ [redacted]ផេង អាយុ៣៨ឆ្នាំ មុខរបររកស៊ី មានទីលំនៅបច្ចុប្បន្នភូមិ[redacted]។

**អ្នកចូលរួមមាន សាក្សី៖**

- **ឈ្មោះ** [redacted]សុខាង ភេទស្រី អាយុ៣៤ឆ្នាំ សញ្ញាតិខ្មែរ សាសនាព្រះពុទ្ធ ទីលំនៅ[redacted]។
- **ឈ្មោះ** [redacted]ថាវី ភេទស្រី អាយុ៥៨ឆ្នាំ សញ្ញាតិខ្មែរ ទីលំនៅ[redacted]។

## អង្គហេតុ និងចំណុចវិវាទ:

**១. ការទាមទាររបស់ដើមចោទ៖**

ដើមចោទប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចដូចខាងក្រោម៖

- បង្គាប់ឱ្យចុងចម្លើយសងប្រាក់មកដើមចោទសរុបទាំងអស់ចំនួន USD៥៤,១០០ (ប្រាំមុឺនបួនពាន់មួយរយដុល្លារអាមេរិក)។



Scanned with CamScanner

- បង្គាប់ឱ្យចុងចម្លើយសងមកដើមចោទនូវប្រាក់សំណងនៃការខូចខាត និងការខាតបង់ពេលវេលាចំនួន USD ១០,០០០ (មួយម៉ឺនដុល្លារអាមេរិកគត់) ។

- ប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់ចុងចម្លើយ ។

- សាលក្រមមានអនុភាពអនុវត្តជាបណ្តោះអាសន្នបានគ្រង់ចំណុចទី១ និងទី២ ខាងលើ ។

**២. ការពន្យល់ត្រួសៗអំពីរឿងក្តី៖**

ក្នុងរឿងក្តីនេះ ដើមចោទឈ្មោះ [redacted] គីមឡុង ជាមេតុងទីន និងចុងចម្លើយឈ្មោះ [redacted] ដារ៉េន និងឈ្មោះ [redacted] អេង ជាកូនតុងទីនបានលេងតុងទីនជាមួយដើមចោទចំនួន៣លើក។ លើកទី១ តុងទីនក្បាល USD២០០ (ពីររយដុល្លាអាមេរិក) ចុងចម្លើយលេងចំនួន៣ក្បាល មានកូនតុងទីនសរុបចំនួន២៨នាក់ ចាប់ផ្តើមវេញលើកទី១ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ និងបញ្ចប់ទៅវិញនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩, លើកទី២ តុងទីនក្បាល USD១០០ (មួយរយដុល្លាអាមេរិក) ចុងចម្លើយឈ្មោះ [redacted] ដារ៉េន លេងចំនួន១០ក្បាល តុងទីនកូនសរុបចំនួន៨៩នាក់ ចាប់ផ្តើមថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ និងក្បាលទី៣ ក្បាលUSD១០០ (មួយរយដុល្លាអាមេរិក) ចុងចម្លើយលេងចំនួន៧ក្បាល កូនសរុប៤២នាក់ ចាប់ផ្តើមប្រមូល៣០ ខែកញ្ញា ២០១៧។ តាមការអះអាងរបស់ដើមចោទឈ្មោះ [redacted] គីមឡុង ចុងចម្លើយឈ្មោះ [redacted] ដារ៉េន និងឈ្មោះ [redacted] អេង បានវេញតុងទីនលើកទី២ និងលើកទី៣ ដាប់អស់គ្មានសល់ ហើយឈប់បង់ចាប់ពីថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ ទាំងដែលកាលបរិច្ឆេទលេងតុងទីនលើកទី២ និងលើកទី៣ នេះមិនទាន់ចប់កាលបរិច្ឆេទនៅឡើយ ធ្វើឱ្យប្រាក់ដែលនៅសល់មិនទាន់បង់ឱ្យដើមចោទនៅចំនួន USD៥៤,១០០ (ប្រាំម៉ឺនបួនពាន់មួយរយដុល្លារអាមេរិក) ហេតុដូច្នេះហើយទើបដើមចោទសម្រេចចិត្តដាក់ពាក្យបណ្តឹងទាមទារប្រាក់ពីចុងចម្លើយតែម្តង។

**៣. ការអះអាងរបស់ភាគីក្នុងកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២១៖**

**- ដើមចោទឈ្មោះ [redacted] គីមឡុង បានធ្វើសេចក្តីថ្លែងការណ៍ថា៖** នាងខ្ញុំសូមរក្សាការថ្លែងការណ៍ទាមទារដូចក្នុងពាក្យបណ្តឹងចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ និងដូចកាលបរិច្ឆេទត្រៀមទាញហេតុផល ទុកជាបានការរដែលដោយធ្វើការទាមទារឱ្យចុងចម្លើយសងប្រាក់ មកនាងខ្ញុំសរុបទាំងអស់ចំនួន USD៥៤,១០០ (ប្រាំម៉ឺនបួនពាន់មួយរយដុល្លារអាមេរិក) ,បង្គាប់ឱ្យចុងចម្លើយសងមកដើមចោទនូវប្រាក់សំណងនៃការខូចខាត និងការខាតបង់ពេលវេលាចំនួន USD១០,០០០ (មួយម៉ឺនដុល្លារអាមេរិកគត់), ប្រាក់ប្រដាប់ក្តី និងការចំណាយលើនីតិវិធីតុលាការជាបន្ទុករបស់ចុងចម្លើយ, សាលក្រមមានអនុភាពអនុវត្តជាបណ្តោះអាសន្នបានគ្រង់ចំណុចទី១ និងទី២ ខាងលើ។ គាត់បង់ឱ្យខ្ញុំហូរហែររហូត ថ្ងៃ៣០ ខែតុលា ឆ្នាំ២០២០ គាត់ឱ្យខ្ញុំបានតែ ២០០០$ ខ្វះ៣០០$។ ខ្ញុំហៅសាក្សីទៅទារគាត់ឆ្លើយថា អត់ទាន់មានលុយទេ ព្រោះមានវិបត្តិកូវីដផង គ្មានលុយ។ ក្រោយមកខ្ញុំឱ្យគេទៅទារ។ ចូលមករា ថ្ងៃទី៣០ គាត់ថា ទូទាត់អស់ហើយលុយនោះ។ គាត់ថាសងខ្ញុំរួចហើយ ប៉ុន្តែសូមបញ្ជាក់ថាតាំងពីបានអោយខ្ញុំ២០០០$មក មិនដែលបានបង់ទេ។ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ វេញចប់អស់ហើយ ក្បាល២០០$ លេងកូន ២៨នាក់ ចាប់វេញថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ ក្នុង១ខែម្តង រៀងរាល់ថ្ងៃទី៣០ គាត់លេង៣ក្បាល ស្មើ៦០០$។ ក្បាលទី២ តុងទីនក្បាល១០០ [redacted] ដារ៉េន លេង១០ក្បាល តុងទីន៨៩នាក់ ចាប់ផ្តើមថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧។ ក្បាលទី៣ ក្បាល១០០ ចំនួន៧ក្បាល កូន៤២នាក់ ចាប់ផ្តើមប្រមូល៣០ ខែកញ្ញា ២០១៧។ គាត់វេញចុងក្រោយ ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩។ គាត់ឈប់បង់ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០។ ក្បាល២០០$ ចប់នៅក្នុងខែមេសា ឆ្នាំ២០២១។ ខែឧសភា ឆ្នាំ២០២១ បង់តែ ១០០០$ទេ ក្រោយមកឈប់បង់រហូត។ ខ្ញុំសូមបញ្ជាក់ជូនតុលាការថា ចុងចម្លើយបានលេងតុងទីន និងបានបង់ឱ្យខ្ញុំក្នុងមួយ ៗ



Scanned with CamScanner

ខែ១៧០០$ (មួយពាន់ប្រាំពីររយដុល្លារ)។ ប្រាក់សរុបដែលដេញបានខ្ញុំមិនចាំទេ ខ្ញុំចាំតែប្រាក់ជំពាក់គឺ៥៤១០០$។ ចុងចម្លើយឈប់បង់ប្រាក់ឱ្យខ្ញុំតាំងពីខែ១០ ឆ្នាំ២០២០ ហើយខ្ញុំបានដាស់តឿនគាត់ជាច្រើនដងមកហើយ គាត់ថាមូលហេតុកូវីដ។ តាំងពីគាត់លេងតុងទីនបានគាត់ដេញបានរហូតមក លើកចុងក្រោយដែលគាត់ដេញបានគឺនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ មួយក្បាលចុងក្រោយចំនួន ៤២១៥ ដុល្លារអាមេរិក ហើយមានផ្តិតមេដៃទទួល។ ចំនួនអ្នកលែងសរុបគឺ៨៩នាក់ ជាអ្នកភូមិ និងគ្រូបង្រៀននៅសាលា។ ខ្ញុំមានសាក្សី និងភស្តុតាងដែលបញ្ជាក់ថាឈ្មោះ នេះមិនបានបង់ឱ្យខ្ញុំគ្រប់ចំនួន។ ខ្ញុំនៅជំពាក់កូនតុងទីនផ្សេងៗទៀតដែរ។ ចំពោះការសម្រុះសម្រួលនៅឃុំ និងស្រុក គាត់បដិសេធរហូតមក។ ខ្ញុំសូមបញ្ជាក់ថាលុយពេលគាត់ទទួលមានផ្តិតម្រាមដៃត្រឹមត្រូវ ហើយគាត់បានផ្តិតម្រាមដៃពេលទទួលប្រាក់ពីខ្ញុំ។

**-ចុងចម្លើយឈ្មោះ [redacted] ដារ៉ែន បានធ្វើសេចក្តីថ្លែងការណ៍តបថា៖** នាងខ្ញុំសូមរក្សាសេចក្តីថ្លែងការណ៍ដូចកាលបរិច្ឆេទត្រៀមទាញហេតុផលដដែល។ នាងខ្ញុំសូមបញ្ជាក់ជូនតុលាការថា នាងខ្ញុំពិតជាបានលេងតុងទីនជាមួយដើមចោទ០៣លើកដូចការអះអាងរបស់ដើមចោទពិតមែន។ លើកទី១៖ តុងទីនក្បាល USD ២០០ (ពីររយដុល្លារអាមេរិក) ចំនួន០៣ ក្បាល មានកូនតុងទីនចំនួន ២៨ នាក់ ចាប់ផ្តើមដេញលើកទី១ នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៦ លើកទី២៖ តុងទីនក្បាល USD ១០០ (មួយរយដុល្លារអាមេរិក) ចំនួន ១០ ក្បាល មានកូនតុងទីនទាំងអស់ចំនួន ៨៩ នាក់ ចាប់ផ្តើមដេញលើកទី១ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧។ លើកទី៣៖ តុងទីនក្បាល USD ១០០ (មួយរយដុល្លារអាមេរិក) ចំនួន០៧ក្បាល មានកូនតុងទីនទាំងអស់ចំនួន៤២នាក់ ចាប់ផ្តើមប្រមូលលើកទី១ នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧។ ខ្ញុំបានលេងពិតមែន ខ្ញុំបានទូទាត់រួចអស់ហើយ។ ខ្ញុំដេញទាំងអស់ក្បាល២០០$ ហើយលេងចំនួន០៣ក្បាល, ក្បាលទី២ ក្បាល១០០$ ខ្ញុំលេង០៧នាក់ ចំនួនសរុប៤២នាក់ , ទី៣ ក្បាល១០០$ ខ្ញុំលេង១០ក្បាល សរុប៤៨នាក់។ កាលបរិច្ឆេទលេងលើកទី១ ខ្ញុំមិនចាំទេ, ក្បាល១០០$ ក៏ខ្ញុំមិនចាំ បើដេញបានខ្ញុំផ្តិតមេដៃឱ្យ។ ខ្ញុំបានផ្តិតម្រាមដៃពិតមែន ប៉ុន្តែ ៤, ៥ ថ្ងៃក្រោយមក បានគាត់ឱ្យលុយខ្ញុំ គាត់ឱ្យមិនគ្រប់ចំនួនទេ គាត់ទូទាត់ កាត់កង១វគ្គៗ ខ្ញុំដេញបានដប់ ខ្ញុំទូទាត់ដប់។ ខ្ញុំអត់បានជំពាក់លុយគាត់ទេ សូម្បីតែ១០០៛។ ខ្ញុំដេញអស់មុនតុងទីនចប់មែន តែពេលដេញបានខ្ញុំទូទាត់កាត់កង។ ខ្ញុំស្គាល់គោលការណ៍នៃការលេងតុងទីនច្បាស់ ដើម្បីសន្សំលុយទុក ខ្ញុំកាត់ទឹកប្រាក់ព្រោះពេលនោះតុងទីនគាត់រញ៉េរញ៉ៃ ទើបខ្ញុំកាត់កង។ គាត់យកមកឱ្យខ្ញុំផ្តិត ខ្ញុំផ្តិតទៅ ខ្ញុំអត់បានមើលក្រដាសទេ។ ខ្ញុំនៅតែអះអាងថាពុំបានជំពាក់លុយដើមចោទទេ។ ខ្ញុំអត់មានសាក្សីទេបញ្ជាក់ទេ រឿងកាត់កងនេះ។ ខ្ញុំសំណូមពរទៅតុលាការថាខ្ញុំអត់មានអីត្រូវទទួលខុសត្រូវទេ ព្រោះខ្ញុំអត់បានជំពាក់។

**-ចុងចម្លើយឈ្មោះ [redacted] រ៉េង បានធ្វើសេចក្តីថ្លែងការណ៍តបថា៖** ខ្ញុំបានផ្តិតពិតមែន គាត់ហៅខ្ញុំផ្តិត ខ្ញុំក៏ផ្តិតពិតមែន ខ្ញុំអត់ដែលបានមើលអក្សរលើក្រដាសទេ។ ខ្ញុំបាទអត់បានលេងទេ ប្រពន្ធខ្ញុំលេង។

**- សាក្សីឈ្មោះ [redacted] សូនាង បានថ្លែងការណ៍ថា៖** នាងខ្ញុំដឹងថាពេលគាត់ដេញហើយ គាត់អត់មានបានបង់ ព្រោះខ្ញុំនៅជិតផ្ទះគាត់ដែរ ហើយខ្ញុំលឺសួរ ពេលមេតុងទីនទៅទារលុយ ចុងចម្លើយថាគាត់អត់លុយ គាត់អត់អោយទេ។ ខ្ញុំអត់មានលឺអ្វីទៀតទេ។ តុងទីនគាត់ងាប់អស់ ហើយគាត់អត់ព្រមបង់អោយគេ មូលហេតុដែលខ្ញុំដឹងរឿងនេះ ព្រោះខ្ញុំជាកូនតុងទីនមួយដែរ ដែលដេញហើយអត់បានលុយ។

**- សាក្សីឈ្មោះ [redacted] ថាវី បានថ្លែងការណ៍ថា៖** ក្នុងរឿងនេះខ្ញុំអ្នកដេញបាន ទៅទារលុយគាត់ តែគាត់អត់លុយអោយខ្ញុំ គាត់ថាបើមានលុយ បានសង ប្តីគាត់និយាយថា បើជំពាក់គេ សងគេទៅ។ គាត់និយាយទៀតថាអត់ពាក់ព័ន្ធជាមួយខ្ញុំទេ។ បើគេមានលុយ បានគេសង បើគ្មានគេមិនសងទេ គាត់និយាយចឹង។ តុងទីនបានទៅលើឈ្មោះ [redacted] ដារ៉ែន ដេញងាប់អស់ហើយ។ ខ្ញុំបានទៅជួបជាមួយ ដារ៉ែន នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ ។ ៤

- ចុងចម្លើយឈ្មោះ [redacted] ដារ៉េន បានធ្វើសេចក្តីថ្លែងការណ៍តបថា៖ ចម្លើយសាក្សីមិនពិតទេ មានតែខ្ញុំ និងមេតុងទីនទេ ខ្ញុំបង់តែ២នាក់មេទេ។ ផ្ទះសាក្សីរំលងផ្ទះ៣នោះ មិចដឹងខ្ញុំបង់ ឬមិនបង់។ ខ្ញុំអត់បានដឹងថាត្រូវធ្វើលិខិតបញ្ចប់លុយតុងទីនទេ។ គាត់ឱ្យខ្ញុំផ្តិតមេដៃ ខ្ញុំមិនដឹងលិខិតអីផង។ ឈ្មោះ ថាវី មិនដែលទៅផ្ទះខ្ញុំទេ។

៤. ចំណុចវិវាទមាន៖

- ភាគីដើមចោទទាមទារប្រាក់ចំនួន USD ៥៤,១០០ (ប្រាំម៉ឺនបួនពាន់មួយរយដុល្លារអាមេរិក) ជាប្រាក់នៅសល់មិនទាន់បង់ឱ្យខ្លួន ក្រោយពីចុងចម្លើយបានដេញយកប្រាក់អស់ ប៉ុន្តែភាគីចុងចម្លើយបានបដិសេធថាបានបង់អស់ហើយ។ តើដើមចោទមានមូលហេតុគតិយុត្តណាមួយដើម្បីបញ្ជាក់ថា ចុងចម្លើយជំពាក់ប្រាក់មិនទាន់បង់ចំនួន USD ៥៤,១០០(ប្រាំម៉ឺនបួនពាន់មួយរយដុល្លារអាមេរិក)?

- ចុងចម្លើយឈ្មោះ [redacted] ដារ៉េន ទទួលស្គាល់ថាបានផ្តិតមេដៃទទួលប្រាក់ដែលបានដេញអស់ប៉ុន្តែបដិសេធ ទទួលគ្រប់ចំនួន។

- ចុងចម្លើយឈ្មោះ [redacted] ដារ៉េន បានអះអាងថា បានបង់ប្រាក់ចប់ជិតមួយឆ្នាំមកហើយ គិតមកដល់ថ្ងៃនេះ ប៉ុន្តែដើមចោទអះអាងថា ចុងចម្លើយបានឈប់បង់ឱ្យខ្លួន នៅអំឡុងខែតុលា ឆ្នាំ២០២០ ដោយនៅសល់ប្រាក់ចំនួន USD ៥៤,១០០ (ប្រាំម៉ឺនបួនពាន់មួយរយដុល្លារអាមេរិក) ទៀតមិនព្រមបង់។

- ចុងចម្លើយបដិសេធចំពោះការទាមទារសំណងការខូចខាត និងខាតពេលវេលា ចំនួន១០,០០០$ (មួយម៉ឺនដុល្លា)។

៥. ការពិនិត្យភស្តុតាងរួមមាន៖

-ពាក្យបណ្តឹងចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ , កំណត់ហេតុនៃការសម្រុះសម្រួល ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ និងរបាយការណ៍បញ្ជូនចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ របស់សាលាឃុំភ្នំកុង។ (ថតចម្លង)

-កំណត់ហេតុនៃការសម្រុះសម្រួល ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១ របស់ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន នៃរដ្ឋបាលស្រុកអង្គរជ័យ។ (ថតចម្លង)

-តារាងបញ្ជាក់តុងទីនក្បាល USD ២០០ (ពីររយដុល្លារអាមេរិក) មានចំនួនកូនលេង២៨នាក់។ (ថតចម្លង)

-តារាងបញ្ជាក់តុងទីនក្បាល USD១០០ (មួយរយដុល្លារអាមេរិក) មានចំនួនកូនលេង៤៩នាក់ ចាប់ផ្តើមប្រមូលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ (ថតចម្លង)

-តារាងបញ្ជាក់តុងទីនក្បាល USD១០០ (មួយរយដុល្លារអាមេរិក) មានចំនួនកូនលេង៤២នាក់ ចាប់ផ្តើមប្រមូលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ (ថតចម្លង)

- លិខិតបញ្ជាក់ពីការដេញតុងទីនរបស់ឈ្មោះ [redacted] ដារ៉េន និងឈ្មោះ [redacted]ផង និងបញ្ជាក់ពីចំនួនទឹកប្រាក់ដែលត្រូវបង់មកមេតុងទីនវិញប្រចាំខែ។ (ថតចម្លង)

## សំអាងហេតុ

**ឆ្លងតាមលទ្ធផលសាកសួរ និងពិនិត្យភស្តុតាងនៅនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ឃើញថា៖**

១. ផ្អែកតាមការអះអាងរបស់គូភាគី ដើមចោទ និងចុងចម្លើយពិតជាមានទំនាក់ទំនងលេងតុងទីនជាមួយគ្នាប្រាកដមែន ហើយចុងចម្លើយបានទទួលស្គាល់ការលេងតុងទីនជាមួយដើមចោទចំនួន៣ខ្សែ សកម្មភាពរបស់ភាគីមានទំនាក់ទំនងគតិយុត្តិជាទម្រង់នៃកិច្ចសន្យា ស្របតាមខ្លឹមសារមាត្រា៣៣៦ នៃក្រមរដ្ឋប្បវេណី ដូច្នេះតុលាការអាចលើកយកមកពិចារណា និងសម្រេចតាមច្បាប់ ។ ៥



Scanned with CamScanner

២. ផ្អែកតាមភស្តុតាង តារាងបញ្ជាក់តុងទីនក្បាល USD ២០០ (ពីររយដុល្លាអាមេរិក) មានចំនួនកូនលេង២៨នាក់, តារាងបញ្ជាក់តុងទីនក្បាល USD១០០ (មួយរយដុល្លាអាមេរិក) មានចំនួនកូនលេង៨៩នាក់ ចាប់ផ្តើមប្រមូលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ និងតារាងបញ្ជាក់តុងទីនក្បាល USD១០០ (មួយរយដុល្លាអាមេរិក) មានចំនួនកូនលេង៤២នាក់ ចាប់ផ្តើមប្រមូលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧។

- តុលាការយល់ឃើញថា ដើមចោទ និងចុងចម្លើយ ពិតជាមានទំនាក់ទំនងក្នុងការលេងតុងទីនប្រាកដមែន ប៉ុន្តែចំណុចវិវាទ គឺទាក់ទងនឹងការលេងខ្សែទី២ និងខ្សែទី៣ ដែលមានក្នុងតារាងបញ្ជាក់តុងទីនក្បាល USD១០០ (មួយរយដុល្លាអាមេរិក) មានចំនួនកូនលេង៨៩នាក់ និងតារាងបញ្ជាក់តុងទីនក្បាល USD១០០ (មួយរយដុល្លាអាមេរិក) មានចំនួនកូនលេង៤២នាក់ ចំពោះការលេងលើកទី១ បានចប់សព្វគ្រប់ហើយគ្មានវិវាទទេ។

**ក. ចំណុចវិវាទទី១៖** ដើមចោទបានលេងជាមួយចុងចម្លើយ ដូចមានបញ្ជាក់ក្នុងឯកសារតារាងតុងទីនដែលមានផ្តិតស្នាមម្រាមដៃ ក្បាល USD១០០ (មួយរយដុល្លាអាមេរិក) ចុងចម្លើយលេង១០ក្បាល មានចំនួនកូនសរុបលេង៨៩នាក់ បូកមេតុងទីនម្នាក់ទៀត៩០នាក់ ចាប់ផ្តើមប្រមូលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ និងចាប់ផ្តើមដេញនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ រយៈពេលលេងគឺ៩០ខែ បើផ្ទៀងផ្ទាត់ពីកាលបរិច្ឆេទចាប់ផ្តើមលេង រហូតដល់បញ្ចប់ខ្សែនេះ គឺនៅកាលបរិច្ឆេទថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ ។

**ខ. ចំណុចវិវាទទី២៖** ដើមចោទបានលេងជាមួយចុងចម្លើយ ដូចមានបញ្ជាក់ក្នុងឯកសារតារាងតុងទីនក្បាល USD ១០០ (មួយរយដុល្លាអាមេរិក) ចុងចម្លើយលេង៧ក្បាល មានចំនួនកូនសរុបលេង៤២នាក់ ចាប់ផ្តើមប្រមូលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ និងចាប់ផ្តើមដេញថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ រយៈពេលលេងគឺ៤២ខែ បើផ្ទៀងផ្ទាត់ពីកាលបរិច្ឆេទចាប់ផ្តើមលេង រហូតដល់បញ្ចប់ខ្សែនេះ គឺនៅកាលបរិច្ឆេទថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១។

៣. យោងតាមលិខិតបញ្ជាក់ពីការដេញតុងទីនរបស់ឈ្មោះ [redacted] ដារ៉ែន និងឈ្មោះ [redacted] ផេង និងបញ្ជាក់ពីចំនួនទឹកប្រាក់ដែលត្រូវបង់មកមេតុងទីនវិញប្រចាំខែ ដែលមានផ្តិតស្នាមម្រាមដៃចុងចម្លើយ និងដើមចោទ ដែលមានខ្លឹមសារបញ្ជាក់ថាចុងចម្លើយបានដេញតុងទីនបានថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៩ ចុងចម្លើយបានដេញងាប់ទាំងអស់ក្នុងមួយខែ ត្រូវបង់១៦០០$ ក្បាល១០០$ +១០០$ ដេញងាប់ ១៦ក្បាល ត្រូវបង់ឱ្យដើមចោទចំនួន១៦០០$ ក្នុងមួយខែជារៀងរាល់ខែ រហូតដល់ចប់កូន។ ផ្អែកតាមការអះអាងរបស់ដើមចោទ ចុងចម្លើយឈ្មោះ [redacted] ដារ៉ែន និងឈ្មោះ [redacted] ផេង បានឈប់បង់នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ ដោយកាលបរិច្ឆេទនៃការលេងតុងទីនមិនទាន់បានចប់នៅឡើយ។

- តាមការអះអាងរបស់ចុងចម្លើយបញ្ជាក់ថា បានដេញអស់ពិតមែន និងបានផ្តិតម្រាមដៃមែន ប៉ុន្តែចុងចម្លើយអះអាងថាដើមចោទឱ្យប្រាក់ខ្លួនមិនគ្រប់ ហើយខ្លួនបានទូទាត់កាត់កងរួចអស់ហើយ គ្មានជំពាក់វាក់វិនគ្នាទេ។ ការអះអាងរបស់ចុងចម្លើយពុំមានឯកសារជាភស្តុតាង ឬសាក្សីបញ្ជាក់មកតុលាការ ពីការដែលទទួលលុយមិនគ្រប់ចំនួន និងការកាត់កងនេះទេ។ ជាគោលការណ៍នៃលេងតុងទីន កូនត្រូវមានកាតព្វកិច្ចបង់មកឱ្យមេតុងទីនវិញនៅរាល់ពេលដែលត្រូវដេញម្តងៗ ចំពោះការបញ្ជាក់របស់ចុងចម្លើយ និងឯកសារដែលបានផ្តិតនៅពេលមេតុងទីនប្រគល់លុយ មានលក្ខណៈផ្ទុយនឹងឯកសារដែលមេតុងទីនបានអះអាង ហើយចុងចម្លើយបញ្ជាក់យ៉ាងច្បាស់ពេលទាញហេតុផលដោយផ្ទាល់មាត់ថា ខ្លួនពិតជាបានផ្តិតម្រាមដៃនៅលើលិខិតទទួលប្រាក់នេះជាមួយប្តីខ្លួនប្រាកដមែន ដែលភស្តុតាងនេះអាចអោយតុលាការជឿបានថា ចុងចម្លើយពិតជាមានកាតព្វកិច្ចបង់ឱ្យដើមចោទជាមេតុងទីន នៅប្រាក់ប្រចាំខែប្រាកដមែន គប្បីតុលាការពិនិត្យ និងសម្រេចតាមច្បាប់។ ១



Scanned with CamScanner

៤. បានឃើញការបំភ្លឺរបស់សាក្សីឈ្មោះ [redacted] សូនាង និងឈ្មោះ [redacted] ថាវី បានចូលមកបំភ្លឺពីទំនាក់ទំនងរវាងការលេងតុងទីនរបស់ដើមចោទ និងចុងចម្លើយ ការដេញយកអស់ និងការជំពាក់ប្រាក់ ការឆ្លើយបំភ្លឺរបស់សាក្សីមានទំនាក់ទំនងជាមួយនឹងអង្គហេតុ ដូច្នេះតុលាការអាចលើកយកមកពិនិត្យពិចារណាបាន។

៥. ដើមចោទបានប្តឹងមកតុលាការឱ្យចេញសាលក្រមបង្គាប់ឱ្យចុងចម្លើយសងប្រាក់ចំនួនUSD៥៤,១០០ **(ប្រាំម៉ឺនបួនពាន់មួយរយដុល្លាអាមេរិក)** ជាប្រាក់នៅសល់មិនទាន់បង់ឱ្យដើមចោទ។ ក្រោយពីតុលាការពិនិត្យ និងផ្ទៀងផ្ទាត់លើការអះអាង និងឯកសារជាភស្តុតាងរួចមក ឃើញថាចុងចម្លើយឈ្មោះ [redacted] **ដារ៉ែន** និងឈ្មោះ [redacted] **ផេង** បានឈប់បង់ប្រាក់នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០២០ ហេតុនេះ៖

-តុងទីនខ្សែទី២ ក្បាលUSD១០០ **(មួយរយដុល្លាអាមេរិក)** ចុងចម្លើយលេងចំនួន១០ក្បាល កូនសរុបមានចំនួន៨៩នាក់ បូកទាំងមេ៩០នាក់ ចាប់ផ្តើមប្រមូលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ និងចាប់ផ្តើមដេញនៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ត្រូវបញ្ចប់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៥ សល់ទឹកប្រាក់មិនទាន់បង់មានចំនួន៥២ខែ ស្មើនឹង**៥២០០០$ (ប្រាំម៉ឺនពីរពាន់ដុល្លារអាមេរិក)** ។

-តុងទីនខ្សែទី៣ ក្បាល USD១០០ **(មួយរយដុល្លាអាមេរិក)** ចុងចម្លើយលេងចំនួន៧ក្បាល ចំនួនកូនសរុបលេងមានចំនួន៤២នាក់ ចាប់ផ្តើមប្រមូលនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៧ និងចាប់ផ្តើមដេញថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ ត្រូវបញ្ចប់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២១ សល់ទឹកប្រាក់មិនទាន់បង់មានចំនួន៥ ខែ ស្មើនឹង **៣៥០០$ (បីពាន់ប្រាំរយដុល្លារអាមេរិក)**។

សរុបមកការលេងតុងទីនខ្សែទី២ និងខ្សែទី៣របស់ចុងចម្លើយ ឃើញថានៅសល់ប្រាក់សរុបចំនួន**៥៥៥០០$ (ប្រាំម៉ឺនប្រាំពាន់ប្រាំរយដុល្លារអាមេរិក)** ដែលចុងចម្លើយត្រូវបង់ជូនដើមចោទ ប៉ុន្តែដើមចោទបានទាមទារប្រាក់ចំនួន**USD៥៤,១០០ (ប្រាំម៉ឺនបួនពាន់មួយរយដុល្លារអាមេរិក)** ដោយផ្អែកតាមការពិនិត្យ និងផ្ទៀងផ្ទាត់ប្រាក់ដែលចុងចម្លើយមិនទាន់បង់គឺប្រហាក់ប្រហែលនឹងប្រាក់ដែលដើមចោទបានទាមទារ ហេតុនេះអាចឱ្យតុលាការជឿបានថាចុងចម្លើយពិតជានៅជំពាក់ប្រាក់ដើមចោទប្រាកដមែន ដូច្នេះគប្បីតុលាការសម្រេចតាមការទាមទាររបស់ដើមចោទ។

៦. ដើមចោទបានដាក់ពាក្យបណ្តឹងមកតុលាការចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០២១ ដើម្បីទាមទារប្រាក់ចំនួន**USD៥៤,១០០ (ប្រាំម៉ឺនបួនពាន់មួយរយដុល្លារអាមេរិក)** ពីចុងចម្លើយ មុនកាលបរិច្ឆេទបញ្ចប់តុងទីន សកម្មភាពរបស់ដើមចោទបានបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ដោយហេតុថាចុងចម្លើយមិនព្រមអនុវត្តកាតព្វកិច្ចបង់ប្រាក់តុងទីនប្រចាំខែឱ្យដើមចោទ ។ យោងតាមមាត្រា៤០៧ ,មាត្រា៤០៨ និងមាត្រា៤០៩ នៃក្រមរដ្ឋប្បវេណី គប្បីតុលាការពិនិត្យ និងសម្រេចតាមច្បាប់។

៧. ដើមចោទបានប្តឹងទាមទារថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងការចំណាយផ្សេងៗលើនីតិវិធីចំនួន **១,០០០០ $ (មួយម៉ឺន) ដុល្លារអាមេរិក** គប្បីតុលាការលើកយកមកពិចារណាទៅលើលទ្ធភាព ជីវភាព និងបំណុលរបស់ចុងចម្លើយ ព្រមទាំងភស្តុតាងតាមកម្រិតជាក់ស្តែង និងការខូចខាតរបស់ដើមចោទដែលបណ្តាលមកពីការមិនអនុវត្តកាតព្វកិច្ចរបស់ចុងចម្លើយ ដោយយោងតាមមាត្រា៣៩៨ **កថាខណ្ឌទី១ វាក្យខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី** ។

៨. ដើមចោទប្តឹងទាមទារសុំឱ្យអនុវត្តសាលក្រមជាបណ្តោះអាសន្ន ត្រង់ចំណុចទី១ និងចំណុចទី២ **នៃពាក្យបណ្តឹង** គប្បីតុលាការពិនិត្យពីភាពចាំបាច់ ឬមិនចាំបាច់ ពិចារណា និងសម្រេចតាមបញ្ញត្តិ**មាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី** ។

៩. ប្រាក់ប្រដាប់ក្តីត្រូវអនុវត្តតាមមាត្រា៦៤ **នៃក្រមនីតិវិធីរដ្ឋប្បវេណី** ។

## សេចក្តីសម្រេចបញ្ចប់

**១** - បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] **ដារ៉ែន** ភេទស្រី អាយុ៣៨ឆ្នាំ និងឈ្មោះ [redacted] **ផេង** ភេទប្រុស អាយុ៣៨ឆ្នាំ សងប្រាក់ចំនួន៥៤១០០$ (ប្រាំម៉ឺនបួនពាន់មួយរយដុល្លារអាមេរិក) ទៅឱ្យដើមចោទឈ្មោះ [redacted] **គីមឡុង** ភេទស្រី អាយុ៤៨ឆ្នាំ។



Scanned with CamScanner

២- បង្គាប់ឱ្យចុងចម្លើយឈ្មោះ [redacted] ដារ៉ែន ភេទស្រី អាយុ៣៨ឆ្នាំ និងឈ្មោះ [redacted] ផេង ភេទប្រុស អាយុ៣៨ឆ្នាំ សង សំណងនៃការខូចខាត ថ្លៃសេវាកម្មច្បាប់ ការខាតបង់ពេលវេលា និងការចំណាយផ្សេងៗលើនីតិវិធីចំនួន ៨.០០០.០០០៛ (ប្រាំបីលានរៀល) ទៅឱ្យដើមចោទឈ្មោះ [redacted] គីមឡុង ភេទស្រី អាយុ៤៨ឆ្នាំ ការទាមទារលើសពីនេះច្រានចោល។

៣ - ច្រានចោលការទាមទាររបស់ដើមចោទ ឱ្យសាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្ន ត្រង់ចំណុចទី១ និង ចំណុចទី២ នៃសេចក្ដីសម្រេចខាងលើនេះ។

៤ - ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

-សាលក្រមនេះ គូភាគីអាចប្ដឹងឧទ្ធរណ៍តាមមាត្រា២៦០ និងមាត្រា២៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ចៅក្រមជំនុំជម្រះ

[redacted]